Policy Khmer & English final 24/4/08 2:43 pm Page 1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

## ស្តីពី

# ការអប់រំកុមារពិការ



**មីនា ២០០៨**

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាបានកសាងគោលនយោបាយស្តីពី ការអប់រំកុមារពិការដែលមានលក្ខណៈទូលំទូលាយ សំដៅធានាដល់កុមារពិការគ្រប់រូបទទួលបានសិទ្ធិក្នុងការអប់រំដូចកុមារទូទៅប្រកបដោយសមធម៌ ។

គោលនយោបាយនេះ ជាផ្នែកមួយជួយគាំទ្រដល់គោលនយោបាយអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងជាលើកដំបូងក្នុងក្របខ័ណ្ឌកម្រិតអប់រំមូលដ្ឋានដើម្បីឈានទៅសម្រេចផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ ២០១៥ ។

តាមរយៈគោលនយោបាយនេះ អ្នកពាក់ព័ន្ធទាំងអស់ ពិសេសក្នុងស្ថាប័នអប់រំយល់កាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការចូលរួមធ្វើអន្តរាគមន៍លើកកម្ពស់ព្រមទាំងផ្តល់លទ្ធភាពដល់កុមារពិការគ្រប់ប្រភេទឱ្យទទួលបានការអភិវឌ្ឍ ដើម្បីប្រែក្លាយជាសមាជិកយ៉ាងសកម្មក្នុងការចូលរួមកសាងសង្គមជាតិនាពេលបច្ចុប្បន្នក៏ដូចជាអនាគត ។

គោលនយោបាយស្តីពី ការអប់រំកុមារពិការបានបង្ហាញខ្លឹមសារសំខាន់ៗ ទាក់ទងទៅនឹងក្របខ័ណ្ឌសកម្មភាព ការកំណត់យុទ្ធសាស្ត្រ និងវិធានការអនុវត្តសំខាន់ៗ ដែលជាចំណុចពិសេសសម្រាប់ជាជម្រើសក្នុងការអនុវត្តទៅតាមភារកិច្ច ។

គោលនយោបាយនេះ បានកំណត់ និងប្រើប្រាស់វចនាសម្ព័ន្ធមានស្រាប់ដែលអាចធានាជោគជ័យស្របតាមបរិបទរបស់កម្ពុជា ព្រមទាំងជាអនុសាសន៍ដើម្បីពង្រឹងវចនាសម្ព័ន្ធនេះឱ្យយកចិត្តទុកដាក់ចំពោះផលប្រយោជន៍កុមារពិការបានកាន់តែប្រសើរឡើង ។

ក្រសួងអប់រំ យុវជន និងកីឡាមានជំនឿជាក់ថា គោលនយោបាយអប់រំកុមារពិការនឹងផ្តល់ឱកាសដល់កុមារពិការទាំងអស់ឱ្យទទួលបានការអប់រំ ពិសេសការដាក់កុមារពិការឱ្យរៀនជាមួយកុមារទូទៅនៅតាមសាលាចំណេះទូទៅ ឬថ្នាក់អប់រំក្រៅប្រព័ន្ធ ដើម្បីឱ្យគេក្លាយខ្លួនជាសមាជិកសកម្មអាចរស់នៅក្នុងសង្គមប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ។

ជាទីបញ្ចប់ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណដល់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបាន និងកំពុងជួយគាំទ្រ និងបន្តចូលរួមផ្តល់សេវាព្រមទាំងលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែល្អប្រសើរពិសេសសេវាអប់រំកុមារពិការ ។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨

ជ.នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

# មាតិកា

អារម្ភកថា........................................................................... ទំព័រ i
១. សាវតារ........................................................................... ទំព័រ ១
២. គោលបំណង........................................................................... ទំព័រ ៣
៣. ក្របខ័ណ្ឌសកម្មភាព និងវិសាលភាព........................................... ទំព័រ ៤
៤. យុទ្ធសាស្ត្រ និងវិធានការអនុវត្តសំខាន់ៗ.......................................... ទំព័រ ៥

## ១. សារតារ

ប្រទេសកម្ពុជាបានឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាមជិតបីទសវត្សរ៍ ធ្វើឱ្យប្រជាជនកម្ពុជាទទួលរងទុក្ខវេទនាយ៉ាងខ្លាំងដែលក្រៅពីស្លាប់ មានខ្លះរបួសហើយឈានទៅពិការ ខ្លះមានជំងឺដោយសារខ្វះស្បៀងអាហារ ខ្វះការថែទាំគាំពារ និងទីជម្រក រួមទាំងការអប់រំទៀតផង ។

បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និង កីឡាបានចាប់ផ្តើមរៀបចំស្ថិតិកុមារពិការនៅក្នុងប្រព័ន្ធព័តិមានគ្រប់គ្រងអប់រំជាបណ្តើរៗ ។ ប៉ុន្តែតាមរយៈការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៤បានឱ្យដឹងថា ជនដែលមានបញ្ហាមើល បញ្ហាចលនា និងបញ្ហាស្តាប់មានរហូតដល់៦៨% នៃចំនួនជនពិការទាំងអស់ ក្នុងនោះមានកុមារី២.៦% និងមានកុមារា២.៩% ដែលមានអាយុចន្លោះពី៥ឆ្នាំ ទៅ១៧ឆ្នាំមិនបានចុះឈ្មោះចូលរៀនដោយសារពិការភាព ។

ប្រឈមនឹងបញ្ហាពិការភាពរបស់កុមារនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអង្គការជាតិ និងអន្តរជាតិបានផ្តួចផ្តើមគំនិតសំខាន់ៗ ដូចជា:

- រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាហត្ថលេខី ក្នុងការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិជាច្រើន ។ រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រសេចក្តីថ្លែងការណ៍សាឡាម៉ាន់កាឆ្នាំ១៩៩៤ស្តីពីការអប់រំកុមារស្ថិតក្នុងសេចក្តីត្រូវការពិសេស ក្របខ័ណ្ឌសកម្មភាពសហស្សវត្សរ៍បីវ៉ាកូឆ្នាំ២០០៣ និង សេចក្តីថ្លែងការណ៍ក្រុងបាងកកឆ្នាំ២០០៦នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។ ការផ្តួចផ្តើមទាំងនេះផ្តល់ការគាំទ្រសិទ្ធិដល់កុមារក្នុងការទទួលការអប់រំប្រកបដោយសមធម៌ តាមរយៈការអប់រំបញ្ចូលគ្នាដែលជាមធ្យោបាយអាទិភាព ។
- រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិ សេចក្តីថ្លៃថ្នូររបស់ជនពិការ ។ ក្នុងមាត្រា៧៤ នៃច្បាប់រដ្ឋធម្មនុញ្ញដែលបានចែងថា រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។
- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះការអប់រំកុមារពិការ ដោយបានបង្កើតច្បាប់ស្តីពីការអប់រំ ។ ជំពូកទី៧ មាត្រាទី៣៨ និង៣៩ បានលើកឡើងពីការអប់រំពិសេស

ពីសិទ្ធិអ្នកសិក្សាពិការ ក្នុងការសិក្សាជាមួយសិស្ស និស្សិតទូទៅក្នុងកម្មវិធីធម្មតា និងកម្មវិធីអប់រំពិសេសសម្រាប់អ្នកសិក្សាពិការ។

- គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាធានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ឱ្យមានឱកាសស្មើៗគ្នាក្នុងការទទួលបានកម្រិតអប់រំមូលដ្ឋាន ក្នុងនិងក្រៅប្រព័ន្ធដោយមិនប្រកាន់កម្រិតជីវភាព ភេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ។ ដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ដោយធានាចំពោះកុមារទាំងអស់នៅឆ្នាំ២០១៥ ក្នុងការទទួលបានកម្រិតអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ។
- ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ ក្រសួងអប់រំ យុវជន និងកីឡាបានចេញប្រកាសបង្កើតការិយាល័យអប់រំពិសេសនៅនាយកដ្ឋានបឋមសិក្សា ដែលមានភារកិច្ចអភិវឌ្ឍការអប់រំកុមារពិការ កុមារជនជាតិភាគតិច កុមារក្រីក្រ កុមារី និងកុមារជួបការលំបាកផ្សេងៗទៀត។
- ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការដោយមានការឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍន៍នានា។ នៅឆ្នាំសិក្សា ២០០០-២០០១ ក្រសួងបានសាកល្បងអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ នៅខេត្តស្វាយរៀង។ បន្ទាប់មកក៏បានពង្រីកកម្មវិធីនេះដល់ទៅ១៥ខេត្តក្រុង ស្មើនឹង១៥ស្រុកខណ្ឌ ១៤កម្រងសាលារៀន ៨០សាលារៀន ព្រមទាំងបានបណ្តុះបណ្តាលគ្រូពីកម្មវិធីអប់រំបញ្ចូលគ្នាចំនួន៨២៤នាក់ ស្រី៣៤១នាក់ និងរៀបចំថ្នាក់សមាហរណកម្មចំនួន៤២ថ្នាក់ នៅតាមបណ្តាខេត្តក្រុងចំនួន១២ សម្រាប់សិស្សពិការភ្នែក និងគ-ថ្លង់។
- ដៃគូអភិវឌ្ឍន៍នានាបានផ្តល់សេវាអប់រំដល់កុមារពិការ ដូចជា អង្គការគ្រួសារថ្មីបានបង្កើតសាលាពិសេសសម្រាប់កុមារគ-ថ្លង់ និងពិការភ្នែក ព្រមទាំងជួយបណ្តុះបណ្តាលភាសាសញ្ញា និងអក្សរស្ទាប ដល់គ្រូក្របខ័ណ្ឌរដ្ឋដែលបង្រៀនថ្នាក់សមាហរណកម្ម។

Policy Khmer & English final 24/4/08 2:43 pm Page 9



- ក្រសួងបានបង្កើតក្រុមអនុវត្តថ្នាក់ខេត្តក្រុង ជាអ្នកពិនិត្យតាមដាន និងសម្របសម្រួលការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នានៅតាមសាលារៀនផ្ទាល់ ក៏ប៉ុន្តែក្រុមការងារនេះនៅខ្វះជំនាញក្នុងការអប់រំដល់គ្រួសារកុមារពិការ និងបច្ចេកទេសគរុកោសល្យដល់គ្រូបង្រៀន ហើយមួយចំនួនទៀតទទួលបន្ទុកការងារច្រើន ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាឱ្យបានជិតដល់ ដែលជាហេតុធ្វើឱ្យដំណើរការនៃកម្មវិធីនេះពុំទាន់មានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយ ។
- ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីសាលាកុមារមេត្រីចាប់ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៥ ។ ក្នុងនោះសកម្មភាពនៃការអប់រំកុមារពិការគឺជាផ្នែកមួយនៃក្របខ័ណ្ឌសកម្មភាពសាលាកុមារមេត្រីដែលមាន៦សមាសភាគ គឺៈ (១) កុមារទាំងអស់បានចូលរៀន (២) ការសិក្សាប្រកបដោយប្រសិទ្ធភាព (៣) សុខភាព សុវត្ថិភាព និងការការពារកុមារ (៤) ការឆ្លើយតបទៅនឹងយេនឌ័រ (៥) ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ និង (៦) ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ។

ហេតុផលនិងកិច្ចខិតខំប្រឹងប្រែងខាងលើទាមទារឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំគោលនយោបាយមួយច្បាស់លាស់សម្រាប់ធានាដល់កុមារពិការ ឱ្យទទួលបាននូវការអប់រំប្រកបដោយសមធម៌ និងមានអនាគតល្អដូចកុមារទូទៅ ដើម្បីចូលរួមអភិវឌ្ឍសង្គមកម្ពុជាឱ្យកាន់តែមានភាពរុងរឿង គ្រប់ស្ថានភាពនិងកាលៈទេសៈ ។

## ២. គោលបំណង

គោលនយោបាយនេះរៀបចំឡើងដើម្បីៈ

- បង្កើនការយល់ដឹងពីពិការភាពដល់គ្រប់ស្ថាប័ន និងអ្នកពាក់ព័ន្ធ

- កំណត់អត្តសញ្ញាណពិការភាព និងផ្តល់អន្តរាគមន៍ទាន់ពេល លើសេវាស្តារលទ្ធភាពពលកម្មដូចជាការព្យាបាលដោយចលនា សេវាសុខភាពដូចជា ការចាក់ថ្នាំបង្ការចំពោះកុមារពិការទាំងអស់ចាប់តាំងពីកំណើតរហូតដល់អាយុ៥ឆ្នាំ
- ផ្តល់ការអប់រំប្រកបដោយគុណភាព រួមទាំងផ្តល់ការអប់រំបំណិនជីវិត ឬ បណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ និងយុវវ័យពិការប្រកបដោយសមធម៌ និងប្រសិទ្ធភាព
- បង្កើនអត្រាប្រមូលកុមារចូលរៀន និងអត្រាគង់វង្ស។

## ៣. ក្របខ័ណ្ឌសកម្មភាព និងវិសាលភាពអនុវត្ត

គោលនយោបាយអប់រំកុមារពិការមានវិសាលភាពចំពោះកុមារទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គ ឬសតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពប្រចាំថ្ងៃធ្វើឱ្យពួកគេមិនអាចអភិវឌ្ឍខ្លួនដូចកុមារទូទៅ។

គោលនយោបាយអប់រំកុមារពិការបានកំណត់ក្របខ័ណ្ឌសកម្មភាព និងវិសាលភាពតាមសមាសភាគទាំង៦ របស់កម្មវិធីសាលាកុមារមេត្រីដូចតទៅ:

### សមាសភាគ ទី១: កុមារទាំងអស់បានចូលរៀន

**វត្ថុបំណង:** ប្រមូលកុមារពិការគ្រប់ប្រភេទ និង គ្រប់ទីកន្លែងឱ្យបានចូលរៀនប្រកបដោយសមធម៌។

### សមាសភាគ ទី២: ការសិក្សាប្រកបដោយប្រសិទ្ធភាព

**វត្ថុបំណង:** ផ្តល់លទ្ធភាពដល់កុមារពិការឱ្យទទួលបានការអប់រំប្រកបដោយគុណភាព តាមរយៈការធ្វើអន្តរាគមន៍ផ្សេងៗ ដែលទាក់ទងទៅនឹងសេវាសុខភាព សេវាស្តារលទ្ធភាពពលកម្មតាមសហគមន៍ និងការរៀបចំកែសម្រួលសេវាអប់រំចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាបឋមភូមិ។

### សមាសភាគ ទី៣: សុខភាព សុវត្ថិភាព និងការការពារកុមារ

**វត្ថុបំណង:** ធានាដល់កុមារពិការគ្រប់រូប និងគ្រប់ប្រភេទឱ្យទទួលបាននូវការការពារ

ទាំងផ្នែកសុខភាព និងសុវត្ថិភាពក្នុងជីវភាពរស់នៅ ក្នុងសាលារៀន គ្រួសារ និងសហគមន៍ ។

**សមាសភាគ ទី៤: ការឆ្លើយតបទៅនឹងយេនឌ័រ**

**វត្ថុបំណង:** ធានាដល់កុមារគ្រប់រូប ពិសេសកុមារីពិការឱ្យបានចូលរៀន និងបានចូលរួមគ្រប់សកម្មភាពក្នុងសាលារៀន និងសង្គមដូចកុមារទូទៅ ។

**សមាសភាគ ទី៥: ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍**

**វត្ថុបំណង:** បង្កើនការយល់ដឹងពីពិការភាព និងតម្រូវការរបស់កុមារពិការឱ្យបានទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធដើម្បីជួយនិងបង្កលក្ខណៈងាយស្រួលឱ្យពួកគេចូលរួមក្នុងការផ្តល់ការអប់រំកុមារពិការ ។

**សមាសភាគ ទី៦: ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ**

**វត្ថុបំណង:** ធានាការគាំទ្រការអនុវត្តកម្មវិធីអប់រំកុមារពិការប្រកបដោយប្រសិទ្ធភាពពីគ្រប់ឋានានុក្រមអប់រំ ។

## ៤. យុទ្ធសាស្ត្រ និងវិធានការអនុវត្តសំខាន់ៗ

ដើម្បីឱ្យការអនុវត្តគោលនយោបាយអប់រំកុមារពិការទទួលបានជោគជ័យ ទាមទារនូវការប្រើប្រាស់យុទ្ធសាស្ត្រ និងវិធានការអនុវត្តសំខាន់ៗ មួយចំនួនដូចខាងក្រោម:

**យុទ្ធសាស្ត្រ ទី១: កំណត់អត្តសញ្ញាណ និងប្រមូលកុមារពិការ**

**វិធានការអនុវត្តសំខាន់ៗ:**

- ធ្វើការបែងចែក និងផ្សព្វផ្សាយគោលនយោបាយអប់រំកុមារពិការ
- រៀបចំឧបករណ៍សម្រាប់ពិនិត្យឬកំណត់អត្តសញ្ញាណកុមារពិការ

- បំប៉នវិធីកំណត់អត្តសញ្ញាណកុមារពិការដល់គណៈកម្មការទ្រទ្រង់សាលា នាយកសាលានិងភ្នាក់ងារសុខភាពតាមភូមិដោយប្រើតារាងកំណត់អត្តសញ្ញាណកុមារពិការ ដើម្បីប្រមូលទិន្នន័យព័ត៌មានកុមារពិការ
- ធ្វើផែនទីខ្នងផ្ទះដើម្បីស្វែងរកកុមារពិការនៅតាមគ្រួសារនីមួយៗ
- ប្រើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងបញ្ជីចុះឈ្មោះចូលរៀនរបស់សាលារៀនដើម្បីកំណត់តម្រូវការ និងផ្តល់ជំនួយគាំទ្រផ្សេងៗដល់កុមារពិការដែលទើបនឹងរកឃើញ
- បង្កើតប្រព័ន្ធបញ្ជូនកុមារពិការទៅមន្ទីរពេទ្យ ឬដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
- ប្រើផែនទីខ្នងផ្ទះ និងប្រើប្រព័ន្ធបញ្ជូនកុមារពិការសម្រាប់ភ្នាក់ងារសុខភាពតាមភូមិ
- ប្រើទម្រង់ស្ថិតិពិការភាពផ្លូវការសម្រាប់ជំរឿនទូទៅ
- ផ្តល់ជំនួយបច្ចេកទេសដល់ភ្នាក់ងារពាក់ព័ន្ធ ដើម្បីបង្កើតឧបករណ៍សម្រាប់កំណត់ប្រភេទពិការដូចជា ទម្រង់តាមដានប្រសិទ្ធភាពសាលារៀនសម្រាប់ប្រមូលទិន្នន័យព័ត៌មានកុមារពិការនៅក្នុងសាលារៀន ។

## យុទ្ធសាស្ត្រ ទី២: ធ្វើអន្តរាគមន៍ទាន់ពេល និងផ្តល់សេវាផ្សេងៗដល់កុមារពិការ

### វិធានការអនុវត្តសំខាន់ៗ:

- ធ្វើទំនាក់ទំនងជាមួយក្រសួងសុខាភិបាលដើម្បីធ្វើអន្តរាគមន៍ទាន់ពេលដូចជា ការចាក់ថ្នាំបង្ការ និងអប់រំបង្ការជំងឺឆ្លងផ្សេងៗ ធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដូចជា សេវាស្តារលទ្ធភាពពលកម្មចាប់ពីកើតរហូតដល់អាយុ៥ឆ្នាំ ពិសេសកុមារដែលរងគ្រោះថ្នាក់ ឬមានបញ្ហាសុខភាពផ្សេងៗ ដែលនឹងអាចក្លាយខ្លួនទៅជាជនពិការ
- ដាក់បញ្ចូលកុមារពិការអាយុពី៣ទៅ៥ឆ្នាំ ឱ្យចូលរៀននៅក្នុងសាលាមត្តេយ្យសិក្សារដ្ឋ ឯកជន សហគមន៍ និងការអប់រំកុមារតូចតាមផ្ទះ
- អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរាល់សកម្មភាពរៀននិងបង្រៀនដោយមានលក្ខណៈទន់ភ្លន់

- អនុវត្តកម្មវិធីអប់រំកុមារអាយុ៦ឆ្នាំ ដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សារៀនថ្នាក់ទី១នៃសាលាបឋមសិក្សា
- អនុវត្តកម្មវិធីបំណិនជីវិតដើម្បីជួយដល់កុមារពិការ
- ដាក់បញ្ចូលកុមារពិការទៅតាមកម្រិតថ្នាក់ស្របនឹងអាយុរបស់គេនៅក្នុងថ្នាក់នៃសាលាចំណេះទូទៅ
- ផ្តល់ការគាំទ្រ និងការបង្រៀនឱ្យស្របនឹងសេចក្តីត្រូវការពិសេសរបស់គេ
- ធ្វើទំនាក់ទំនងជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈក្រោយពីបញ្ចប់កម្រិតអប់រំមូលដ្ឋាន ។

## យុទ្ធសាស្ត្រ ទី៧: ផ្តល់ឱកាស និងអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នា

**វិធានការអនុវត្តសំខាន់ៗ:**

- ផ្តល់សម្ភារឧបទេសសម្រាប់រៀននិងបង្រៀន ឧបករណ៍ជំនួយដូចជា អវៈយវៈសិប្បនិម្មិត ឈើច្រត់ រទេះរុញ...និងសម្រួលហេដ្ឋារចនាសម្ព័ន្ធសាលារៀនដូចជា ជម្រាល បង្គន់ សួនច្បារកុមារពិការ... ឱ្យស្របតាមបទដ្ឋានសកល
- ផ្តល់មធ្យោបាយធ្វើដំណើរ ឬបង្កលក្ខណៈងាយស្រួលដល់កុមារពិការ ដើម្បីជួយសម្រួលក្នុងការធ្វើដំណើរទៅសាលារៀន
- សម្រួលដល់សិស្សពិការរាល់កម្មវិធីសិក្សាប្រឡងថ្នាក់ជាតិ និងការធ្វើតេស្តផ្សេងៗ ។

## យុទ្ធសាស្ត្រ ទី៨: បង្កើនចំនួនកុមារីពិការឱ្យបានចូលរៀនកាន់តែច្រើន

**វិធានការអនុវត្តសំខាន់ៗ:**

- ប្រមូលស្ថិតិកុមារីពិការ ដើម្បីឱ្យគេបានចុះឈ្មោះចូលរៀនគ្រប់ៗគ្នា
- បញ្ចូលសមាសភាពស្ត្រីពិការដែលមានសមត្ថភាពឱ្យចូលរួមសកម្មភាពសាលារៀនដូចជាសមាជិកគណៈកម្មការទ្រទ្រង់សាលាជាដើម ដើម្បីជាការលើកទឹកចិត្ត និង ជាគំរូសម្រាប់កុមារីពិការដទៃទៀត

- ផ្តល់រង្វាន់លើកទឹកចិត្ត ឬរៀបចំកម្មវិធីសមស្រប ដើម្បីសម្រួលដល់កុមារីពិការឱ្យបាន ជួយទាំងការងារផ្ទះ ការងារសាលារៀន និងការងារសង្គម
- ផ្តល់អាហារូបករណ៍ដល់កុមារីពិការដើម្បីឱ្យពួកគេបានចូលរៀន និងរៀនបន្តឱ្យបានរហូត ចប់កម្រិតអប់រំមូលដ្ឋាន ( ៩ឆ្នាំ )
- សម្របសម្រួលការអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងពីពិការភាព និងផលិត ឯកសារដើម្បីលើកកម្ពស់តួនាទីរបស់កុមារីពិការ និងស្ត្រីពិការក្នុងការងារអប់រំ
- បណ្តុះបណ្តាលពីកម្មវិធីបំណិនជីវិតដល់កុមារីពិការនៅមធ្យមសិក្សាបឋមភូមិ
- ផ្តល់ឱកាសជូនដល់ស្ត្រីពិការឱ្យទទួលបានតួនាទីសក្តិសមក្នុងការគ្រប់គ្រងសាលារៀន និងក្នុងជួរគណៈកម្មការគ្រប់គ្រងផ្សេងៗ ។

## យុទ្ធសាស្ត្រ ទី៩: ផ្សព្វផ្សាយលើការយល់ដឹងពីពិការភាព

### វិធានការអនុវត្តសំខាន់ៗ:

- ពង្រឹងការផ្សព្វផ្សាយ និងអនុវត្តសេចក្តីណែនាំផ្សេងៗ ដែលទាក់ទងនឹងពិការភាពដល់គ្រប់ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ កម្រងសាលារៀន ស្ថាប័នពាក់ពន្ធ ដៃគូអភិវឌ្ឍន៍នានា អ្នកពាក់ព័ន្ធ និងសហគមន៍
- បង្កើតក្រុមមិត្តជួយមិត្តសម្រាប់ជួយកុមារពិការ គ្រប់សកម្មភាពទាំងក្នុងនិងក្រៅ សាលារៀន
- ផ្តល់តួនាទីគំរូដោយអញ្ជើញជនពិការចូលរួមក្នុងសកម្មភាពសាលារៀនដូចជា ក្នុង សកម្មភាពគណៈកម្មការទ្រទ្រង់សាលារៀនជាដើម
- ផ្សព្វផ្សាយការណែនាំពីការសម្រួលហេដ្ឋារចនាសម្ព័ន្ធសាលារៀនដូចជា ជម្រាល បង្គន់ ស្ទួនច្បារកុមារពិការដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ កម្រងសាលារៀន និងសាលារៀន

- ផ្ដល់ព័ត៌មានពីសេវាកម្មថែទាំព្យាបាលកុមារពិការរបស់ដៃគូអភិវឌ្ឍន៍នានា ដើម្បីឱ្យអ្នករស់នៅក្នុងតំបន់ខ្វះសេវា រៀបចំយន្ដការបញ្ជូនកុមារពិការទៅកន្លែងដែលមានសេវាកម្មគ្រប់គ្រាន់
- លើកកម្ពស់ការយល់ដឹងពីពិការភាព និងសិទ្ធិកុមារក្នុងការទទួលការអប់រំ
- លើកទឹកចិត្តមាតាបិតារបស់កុមារពិការឱ្យបង្កើតក្រុមជួយខ្លួនឯង ដើម្បីលើកកម្ពស់ការយល់ដឹង ចែករំលែកព័ត៌មាន បទពិសោធ បង្កើនប្រាក់ចំណូល និងការស្វែងរកការគាំទ្រ។

## យុទ្ធសាស្ត្រ ទី៦: គាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ

### វិធានការអនុវត្តសំខាន់ៗ:

- រៀបចំខ្លឹមសារកម្មវិធីអប់រំបញ្ចូលគ្នា ដើម្បីបញ្ចូលទៅក្នុងកម្មវិធីសាលាកុមារមេត្រី
- រៀបចំសម្ភារឧបទេសឱ្យស្របតាមមេរៀននៃកម្មវិធីអប់រំបញ្ចូលគ្នា
- បណ្ដុះបណ្ដាលកម្មវិធីអប់រំបញ្ចូលគ្នា ដែលជាសមាសភាគមួយនៃកម្មវិធីសាលាកុមារមេត្រី ដល់គរុសិស្ស គរុនិស្សិតនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- បណ្ដុះបណ្ដាលពីវិធីសាស្ត្របង្រៀនអក្សរស្ទាប និងភាសាសញ្ញាដល់គ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រួចបណ្ដុះបណ្ដាលបន្តទៅគរុសិស្ស គរុនិស្សិត និងគ្រូបង្រៀន
- បែងចែកគ្រូឱ្យទៅបម្រើការងារដល់មូលដ្ឋានដែលមានកុមារពិការរស់នៅ
- សហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីបង្កើតមជ្ឈមណ្ឌលធនធាន សម្រាប់ការបណ្ដុះបណ្ដាលគ្រូផ្នែកអប់រំពិសេស
- សហការជាមួយអង្គការជាតិ និងអន្ដរជាតិដើម្បីបណ្ដុះបណ្ដាលគ្រូ នៅតាមសាលាបឋមសិក្សាទូទាំងប្រទេសពីកម្មវិធីអប់រំបញ្ចូលគ្នា វិធីសាស្ត្របង្រៀនអក្សរស្ទាបនិងភាសាសញ្ញា
- បង្កើតស្ដង់ដាគុណភាពដើម្បីវាស់វែង វាយតម្លៃពីភាពរីកចម្រើន និងការអនុវត្តកម្មវិធីអប់រំកុមារពិការ។

KINGDOM OF CAMBODIA
Nation Religion King

Ministry of Education Youth and Sport

# Policy
## On
## Education for Children with Disabilities

March 2008

# Preface

The Ministry of Education, Youth and Sports of the Royal Government of Cambodia has developed the National Policy on Education for Children with Disabilities to ensure the equal rights of all children with disabilities to an equal education with non-disabled children.

This policy supports Child Friendly Schools policy and implementation guidelines that the Ministry in order to achieve basic education initiatives, and the Education Strategic Plan (ESP), as well as Education For All (EFA) goals, by the year 2015.

This policy delineates the roles and responsibilities of all stakeholders, particularly educational institutions, in developing the potential of children with disabilities and providing appropriate interventions to increase the participation of children with disabilities as active members of their communities and nation now and in the future.

The Policy on Education for Children with Disabilities contains the rationale for the policy, provides a conceptual framework and describes strategies and main implementation plan that are specific to the various stakeholders involved.

This policy identifies and uses existing structures currently viable within Cambodia for successful and sustainable implementation, and also makes recommendations for strengthening structures that would further benefit children with disabilities.

The MoEYS strongly hopes that the Policy for Education for Children with Disabilities will give students with disabilities the opportunity to obtain an education, both formal and non-formal, with their regular peers in public schools to enable them to become successful and productive members of society.

Finally, the MoEYS would like to thank all of the other relevant ministries, institutions and development partners that have provided and continue to provide services and contribute to improve the quality of education particularly for children with disabilities.

Phnom Penh, ...28 March.....2008

**For the Senior Minister,**
**Ministry of Education Youth and Sport**
**Secretary of State**

IM-SETHY

Policy Khmer & English final 24/4/08 2:43 pm Page 21



# Table of Contents

Preface ........................................................................ page i

1. Background ..........................................................page 1

2. Aim ........................................................... page 3

3. Conceptual Framework ......................................... page 3

4. Strategies and Main Implementation Plan ................. page 4

# 1. Background

After nearly three decades of civil war, political stability has just returned to Cambodia. During the war, many Cambodian people died of starvation and great hardship. Many others became disabled from war injuries or lack of nutrition and shelter, and still others have been traumatized and have become chronic patients. The educational system was destroyed.

Currently, the Ministry of Education, Youth and Sports (MoEYS) has started to maintain statistics on children with disabilities through the Education Management Information Systems (EMIS). The 2004 Cambodia Socio-Economic Survey (CSES) found that vision and hearing disabilities as well as mobility-related disabilities together account for 68% of all reported disabilities and that 2.6% of girls and 2.9% of boys between the ages of 5 to 17 years did not attend school due to disabilities.

To face the issues of disabilities, several international and national initiatives, which the Royal Government of Cambodia (RGC) supports, provide the rationale and context for the education of children with disabilities:

- The Royal Government of Cambodia is a signatory to all key, legally binding UN human rights treaties. It supports the 1994 Salamanca Statement on Special Needs Education, the 2003 Biwako Millennium Framework for Action and the 2006 Bangkok Convention on the Protection and the Promotion of the Rights of People with Disabilities. These international initiatives support as a priority the child's right to access education through inclusive education.

- The Royal Government of Cambodia recognizes and respects the fundamental human rights and dignity of persons with disabilities. Article 74 of its constitution affirms,

  > "The State shall assist the disabled and the families of combatants who sacrificed their lives for the nation."

- The Education Law, chapter 7, Articles 38 and 39 addresses special education specifically regarding the rights of the learners with disabilities to learn with the non-disabled children and provide a special education service for learners with disabilities.

- The policy of the Ministry of Education, Youth and Sport is to ensure to all children and youth, access to basic education, formal or non-formal, regardless of the children's standard of living, gender, geographic location, physical appearance and ethnicity. To achieve its goals of providing Education For All (EFA), the Ministry has developed an Education Strategic Plan (ESP) and Education Sector Support Program (ESSP), to ensure that all Cambodian children will receive a nine-year basic education by 2015.

- On 31st January 2000, the Ministry of Education Youth and Sport set up the Special Education office in the Primary Education Department, with the responsibility for the educational development of children with disabilities, ethnic minority children, poor children, girls and other disadvantaged children.

- With the collaboration of the Disability Action Council (DAC) and funded by UNICEF, in 2000-2001, the Ministry of Education Youth and Sport implemented the inclusive education (IE) pilot project for children with disabilities in one cluster school in Svay Rieng province. This has expanded to 15 provinces, 15 districts, 14 cluster schools and 80 schools, with training to 824 teachers (341 females). In addition, there are 42 integrated classes in 12 provinces for deaf and for blind children.

- Other development partners have provided educational services to children with disabilities. For example, Krousar Thmey (KT) has established special schools for deaf and blind children, and has trained government teachers in Sign Language and Braille to teach in integrated classes in public schools.

- The Ministry of Education, Youth and Sport has set up Provincial Implementation Teams (PITs) to manage, coordinate and monitor the Inclusive Education (IE) project for children with disabilities in the schools. However, due to a lack of time and technical expertise for working with children with disabilities, PIT members were unable to provide the necessary support to teachers who teach children with disabilities. As a result, the IE project implementation has not been as effective as the Ministry had hoped.

- The Ministry of Education Youth and Sport has implemented the CFS program since 21st November 2005. Education for children

with disabilities is included in the CFS framework; the 6 dimensions being: (1) All children have access to schooling (Schools are inclusive), (2) Effective Teaching and Learning, (3) Health, Safety and Protection of Children, (4) Gender Responsiveness, (5) the participation of children, families and communities in the running of their local school and (6) The National Education System supports and encourages schools to become more child friendly.

The above context provides the rationale for a policy, which guarantees an education for children with disabilities that will enable them to be as successful and contribute to their society as non-disabled children in Cambodia.

## 2. Aim

The aim of this policy is to:

- Increase awareness and acceptance of disabilities among communities, relevant institutions and stakeholders.
- Provide early identification and intervention through rehabilitation services, such as physiotherapy, and health services, e.g. immunization, to all children with disabilities from birth to five.
- Provide quality education, life skills or vocational training to children and youth with disabilities equitably and effectively.
- Increase enrollment, promotion and survival rates in the schools.

## 3. Conceptual Framework

The Policy on Education for Children with Disabilities is designed to serve those children who have difficulty with daily life activities that may interfere with their development like non-disabled children.

*Dimension 1*: **All children have access to schooling (Schools are Inclusive)**

*Objective*: To identify and enroll all children with disabilities in all communities in Cambodia.

*Dimension 2*: **Effective Teaching and Learning**

*Objective*: To provide children with disabilities educational

services appropriate to their needs, such as health, community rehabilitation and modifications of educational services from pre-school to lower secondary school.

*Dimension 3*: **Health, Safety and Protection of Children**
*Objective*: To ensure all children with disabilities the same guarantees of health and safety in their lives at schools, in families and communities.

*Dimension 4*: **Gender Responsiveness**
*Objective*: To ensure all children, especially girls with disabilities, access to schools and their participation in all school and social activities similar to non-disabled children.

*Dimension 5*: **The Participation of Children, Families and Communities in the Running of Their Local School**
*Objective*: To increase awareness and acceptance of disability, and the needs of children with disabilities, within communities and among stakeholders to provide the education of children with disabilities.

*Dimension 6*: **Program Support from the Education System**
*Objective*: To ensure support for the education of children with disabilities effectively from all levels of the education system.

## 4. Strategies and Main Implementation Plan

To effectively and successfully support the policy implementation for the education of children with disabilities, the following strategies will be followed:

***Strategy 1*: Identify and enroll children with disabilities.**

***Implementation Guidelines:***

- Distribute, and raise awareness, of the policy on education for children with disabilities.
- Develop tool for identification of children with disabilities.
- Train school support committees, school principals and village health workers to identify children with disabilities using a simple identification checklist or a screening toolkit in order to collect statistics.
- Conduct community mapping to identify children with disabilities in each family.
- Use school enrollment register and EMIS data in order to identify learning needs and provide appropriate support to children with disabilities,
- Establish a referral system for children with disabilities to hospitals or development partners for follow up.
- In order to refer children with disabilities, utilize community mapping and a referral system for village health workers.
- Utilize the official checklist format that is used in the general census.
- Provide technical assistance to relevant agencies and stakeholders, on developing identification tools in the school effectiveness form for collecting disabilities statistics.

### *Strategy 2:* Implement early intervention and other services to children with disabilities

***Implementation Guidelines:***

- Establish linkages with the Ministry of Health for early intervention such as: immunization and health education on communicable diseases and the Ministry of Social Affairs, Veterans and Youth Rehabilitation for rehabilitation for children from birth to 5 years old, particularly children who are at risk of becoming disabled.
- Place children with disabilities ages 3 to 5 years in community/ state/private pre-schools and home-based programs.
- Apply child-centered principles reasonably to all teaching and learning activities for children with disabilities.
- Implement school readiness programs (SRP) for 6-year-old children who are in grade 1 of primary school and have not passed preschool.

- Provide life skills activities and programs to support children with disabilities.
- Placement age-appropriate in regular classrooms.
- Provide appropriate supports and differentiated instruction regarding to their special needs.
- Collaborate with Ministry of Labor and Vocational Training institutions and development partners to provide vocational training after basic education.

## *Strategy 3*: Provide the opportunity for, and implement, an inclusive education program

### *Implementation Guidelines:*

- Provide teaching aids and assistive devices: prostheses, orthoses, mobility aids, wheel chairs, adapted learning materials, and barrier-free infrastructures for accessibility (ramps, toilets, and playgrounds) following Universal Design standards.
- Provide and coordinate transportation to and from school.
- Provide modifications or alternative assessments on national standardized tests.

## *Strategy 4:* Increase the enrollment of girls with disabilities

### *Implementation Guidelines:*

- Collect statistics of girls with disabilities in order to enroll them in schools.
- Develop role models by inviting women with disabilities to participate in school activities, e.g., school support committees.
- Award non-monetary incentives or provide shift or schedule flexibility to girls with disabilities to come to school, help at home and participate in community tasks.
- Provide scholarships to girls with disabilities to attend school and complete basic education (9 years).
- Coordinate awareness-raising activities and develop training materials to promote the role of girls/women with disabilities in education.
- Provide life skills training to girls with disabilities by attending vocational training at lower secondary school.

- Provide opportunities for women with disabilities in school management and other committees.

## *Strategy 5:* Raise awareness about understanding of disability

***Implementation Guidelines:***

- Effectively disseminate implementation Plan concerning disabilities to all Provincial and District Offices of Education, cluster schools, development partners, stakeholders and communities.
- Establish peer groups that offer support to children with disabilities, e.g., child-to-child activities, within and outside schools.
- Develop role models by inviting people with disabilities to participate in school activities, e.g., school support committees.
- Provide specific information about infrastructure for school accessibility, e.g., ramps, toilets, playgrounds for children with disabilities, to provincial and district offices of education, cluster schools and schools.
- Provide visual information on availability of services, gaps in services and referral routes.
- Promote the understanding of disabilities and child rights to an education.
- Encourage parents of children with disabilities to set up self-help groups to strengthen understanding for information sharing, experiences, income generation and advocacy.

## *Strategy 6:* Support program from the education system

***Implementation Guidelines:***

- Develop an Inclusive Education module with appropriate instructional materials to accompany the modules on Child Friendly Schools.
- Develop teaching aids to access the Inclusive Education module.
- Provide training in Inclusive Education as a component of Child Friendly Schools to all pre-service trainees in Provincial and Regional Teacher Training Colleges.
- Provide certified training in Braille instruction and Sign Language through the Provincial and Regional Teacher Training Colleges to selected trainers, and then provide cascade training to pre/in-service teachers.

Policy Khmer & English final 24/4/08 2:43 pm Page 30



- Place more teachers in rural and remote areas where the children with disabilities live.
- Collaborate with development partners and stakeholders to set up resource centers for teacher training in special education.
- Collaborate with NGOs and IOs to train classroom teachers on inclusive education, Braille and sign language module.
- Establish a quality standard to measure and evaluate the progress of program implementation for education of children with disabilities.

